# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១២៤ សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារចម្រុះ ទទួល និងដោះស្រាយបណ្តឹងតវ៉ាគ្រប់មុខសញ្ញា នៅមុខភូមិគ្រឹះសម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត និងលោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា

## សម្រេច

**ប្រការ ១ :** ត្រូវបានបង្កើតក្រុមការងារចម្រុះ ទទួល និងដោះស្រាយបណ្តឹងតវ៉ាគ្រប់មុខសញ្ញា នៅមុខភូមិគ្រឹះសម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី និងលោកជំទាវបណ្ឌិត ដែលមានសមាសភាពដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១- ឯកឧត្តម នាយឧត្តមសេនីយ៍ | **ហ៊ីង ប៊ុនហៀង** | អគ្គមេបញ្ជាការរង កងយោធពលខេមរភូមិន្ទ នាយកងឧទ្ទកាល័យសម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី | ប្រធាន |
| ២- ឯកឧត្តម ឧត្តមសេនីយ៍ឯក | **ចៅ តុល** | នាយកងឧទ្ទកាល័យសម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី មេបញ្ជាការរង បញ្ជាការដ្ឋានអង្គរក្ស | អនុប្រធាន |
| ៣- ឯកឧត្តម | **ម៉ុក ចំនួសុធា** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី និងជាទីប្រឹក្សាផ្ទាល់សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី | អនុប្រធាន |
| ៤- ឯកឧត្តម អភិបាលនៃគណៈអភិបាល រាជធានីភ្នំពេញ | | | អនុប្រធាន |
| ៥- ឯកឧត្តម អភិបាលនៃគណៈអភិបាល ខេត្តកណ្តាល | | | អនុប្រធាន |
| ៦- ឯកឧត្តម ឧត្តមសេនីយ៍ឯក | **អ៊ុង សារិទ្ធ** | មេបញ្ជាការរង និងជានាយសេនាធិការបញ្ជាការដ្ឋានអង្គរក្ស | សមាជិក |
| ៧- ឯកឧត្តម ឧត្តមសេនីយ៍ឯក | **ឡៀង សារុន** | មេបញ្ជាការរង បញ្ជាការដ្ឋានអង្គរក្ស | សមាជិក |
| ៨- ឯកឧត្តម ឧត្តមសេនីយ៍ឯក | **គោគ ចន្ថា** | មេបញ្ជាការរង បញ្ជាការដ្ឋានអង្គរក្ស | សមាជិក |
| ៩- ឯកឧត្តម ឧត្តមសេនីយ៍ឯក | **ណុប រ័ត្ននិមល** | ជំនួយការសម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី និងជាមេបញ្ជាការរង បញ្ជាការដ្ឋានអង្គរក្ស | សមាជិក |
| ១០- ឯកឧត្តម ឧត្តមសេនីយ៍ឯក | **យ៉ាត ឆូច** | ជំនួយការសម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី និងជាមេបញ្ជាការរង បញ្ជាការដ្ឋានអង្គរក្ស | សមាជិកអចិន្ត្រៃយ៍ |
| ១១- ឯកឧត្តម | **នៅ វ៉ា** | ជំនួយការសម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី | សមាជិក |



CamScanner

១២- ឯកឧត្តម គង់ ចំរើន ជំនួយការសម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី សមាជិក
១៣- ឯកឧត្តម ស៊ុយ ឈុនឆាត់ មេធាវីប្រចាំបញ្ជាការដ្ឋានអង្គរក្ស សមាជិក
១៤- ឯកឧត្តម ឧត្តមសេនីយ៍ឯក ឈិន ចាន់ធួន មេបញ្ជាការ កងអន្តរាគមន៍៩៩៤ (ប្រចាំការភ្នំពេញ) សមាជិក
១៥- ឯកឧត្តម ឧត្តមសេនីយ៍ឯក អ៊ិន សារិន មេបញ្ជាការរង កងអន្តរាគមន៍ទី៤ (ប្រចាំការតាខ្មៅ) និងជាប្រធានប៉ុស្តិ៍ច្រកចូល (K12) សមាជិក
១៦- ស្នងការ ស្នងការដ្ឋាននគរបាល រាជធានីភ្នំពេញ សមាជិក
១៧- មេបញ្ជាការ កងរាជអាវុធហត្ថរាជធានីភ្នំពេញ សមាជិក
១៨- ស្នងការ ស្នងការដ្ឋាននគរបាល ខេត្តកណ្តាល សមាជិក
១៩- មេបញ្ជាការ កងរាជអាវុធហត្ថ ខេត្តកណ្តាល សមាជិក
២០- តំណាងក្រសួងយុត្តិធម៌ ០១ រូប សមាជិក
២១- តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ០១ រូប សមាជិក
២២- តំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ០១ រូប សមាជិក
២៣- តំណាងក្រសួងបរិស្ថាន ០១ រូប សមាជិក
២៤- តំណាងក្រសួងអធិការកិច្ច ០១ រូប សមាជិក
២៥- តំណាងក្រសួងព័ត៌មាន ០១ រូប សមាជិក។

**ប្រការ ២ :** ក្រុមការងារចម្រុះ មានភារកិច្ច ៖

- ទទួលពាក្យបណ្តឹងតវ៉ាផ្សេងៗ នៅមុខភូមិគ្រឹះសម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី និងលោកជំទាវបណ្ឌិត នៅរាជធានីភ្នំពេញ និងខេត្តកណ្តាល រួចបញ្ជូនទៅជំនាញពាក់ព័ន្ធ ឬធ្វើរបាយការណ៍គោរពស្នើសុំគោលការណ៍ដឹកនាំ ឬពិនិត្យសម្រេចដ៏ខ្ពង់ខ្ពស់ពីសម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- សហការជាមួយអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធគ្រប់ជាន់ថ្នាក់ទាំងអស់ ទប់ស្កាត់ក្រុមអ្នកតវ៉ាដែលមានមនុស្សច្រើននាក់ ក្នុងបំណងមកដាក់ពាក្យបណ្តឹងតវ៉ាផ្សេងៗ ជូនសម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី និងលោកជំទាវបណ្ឌិត ដោយព្យាយាមពន្យល់អំពីនីតិវិធីជូនក្រុមអ្នកតវ៉ា ឱ្យយល់អំពីច្បាប់ និងឯកសារផ្សេងៗដែលពាក់ព័ន្ធ
- ទប់ស្កាត់រាល់ការញុះញង់ពីក្រុមឆ្លៀតឱកាសដែលកេងចំណេញមកលើក្រុមអ្នកតវ៉ា
- អនុប្រធាន និងសមាជិក ក្រុមការងារចម្រុះត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានក្រុមការងារ ។

**ប្រការ ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានស្ថាប័នដែលមានការពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

ថ្ងៃព្រហស្បតិ៍ ១៣ កើត ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២៣
**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- អគ្គបញ្ជាការដ្ឋាន កងយោធពលខេមរភូមិន្ទ
- អគ្គស្នងការដ្ឋាន នគរបាលជាតិ
- កងរាជអាវុធហត្ថលើផ្ទៃប្រទេស
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ



https://t.me/oa_channel
CamScanner